**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងធម្មការ និង សាសនា
លេខ ០៨/២១ ក.ធ.ស.សរណន

**សារាចរណែនាំ**
**ស្តីពី**
**ការវាយគង ជួង គោះរគាំង ទូងស្គរ តាមវត្តអារាម**
**ដើម្បីចូលរួមទប់ស្កាត់ស្កាត់ការរាលដាលនៃជំងឺកូវីដ-១៩**
**ក្នុងសហគមន៍ នៃព្រឹត្តិការណ៍ ២០កុម្ភៈ**

យោងអនុសាសន៍ណែនាំដ៏ខ្ពង់ខ្ពស់របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** នៅថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១២១ វេលាម៉ោង ១០:៤១នាទីព្រឹក ។ ក្រសួងធម្មការ និងសាសនា សូមជម្រាបមក លោកប្រធានមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត ជ្រាបថា៖ ដោយសារស្ថានភាពនៃជំងឺកូវីដ-១៩ មានការរាតត្បាតក្នុងសហគមន៍កាន់តែធ្ងន់ធ្ងរឡើង សូមលោកប្រធានមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត សហការជាមួយព្រះមេគណ ព្រះគ្រូអនុគណ ធ្វើការណែនាំទៅគ្រប់វត្តអារាមទាំងអស់ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ឱ្យវាយគង ជួង រគាំង ទូងស្គរ ព្រមៗគ្នាទាំងអស់ ជាសញ្ញាផ្សព្វផ្សាយព័ត៌មាន ដល់ប្រជាពលរដ្ឋ ពុទ្ធបរិស័ទ ឱ្យបង្កើនការប្រុងប្រយ័ត្ន ដោយអនុវត្តនូវវិធានការ «៣ការពារ» និង «៣ កុំ» របស់ប្រមុខរាជរដ្ឋាភិបាល និងតាមការណែនាំរបស់ក្រសួងសុខាភិបាល រហូតដល់ចប់ព្រឹត្តិការណ៍ ២០កុម្ភៈ ឱ្យបាន ០៥ដងក្នុង ០១ថ្ងៃ តាមពេលវេលាកំណត់ ដូចខាងក្រោម៖

លើកទី១ នៅម៉ោង ៥ : ០០ នាទីព្រឹក
លើកទី២ នៅម៉ោង ១១ : ០០ នាទីព្រឹក
លើកទី៣ នៅម៉ោង ២ : ០០ នាទីរសៀល
លើកទី៤ នៅម៉ោង ៥ : ០០ នាទីល្ងាច
លើកទី៥ នៅម៉ោង ៨ : ០០ នាទីយប់

ទទួលបានសារាចរណែនាំនេះ សូម លោកប្រធានមន្ទីរធម្មការ និងសាសនារាជធានី-ខេត្ត ចូលរួមសហការ និងផ្សព្វផ្សាយដល់គ្រប់វត្តអារាមទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយស្មារតីទទួលខុសត្រូវខ្ពស់។

ថ្ងៃ ខែ ផ្លាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២១
**រដ្ឋមន្ត្រី**

ឈិត_សុខុន

<u>ចម្លងជូន-ជូន:</u>
-សម្តេចព្រះមហាសង្ឃរាជទាំងពីរគណ:
-សម្តេចព្រះសង្ឃនាយកទាំងពីរគណ:
-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
-រដ្ឋបាលរាជធានី-ខេត្ត
«ដើម្បីគោរពជូនជ្រាប»
-ឯកសារ-កាលប្បវត្តិ

សួនច្បារសម្តេច ហ៊ុន សែន សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៦៩៩ ទូរសារ : (៨៥៥-២៣) ៧២៥ ៦៩៩ អ៊ីម៉ែល : ministry religion@yahoo.com Web site : www.mocar.gov.kh